ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ...១៦១/២៦... ក.ប/ខ.ស

សារលិខិតជូនពរ

សូមគោរពជូន

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឌិត មុន្នី

ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសចម្រើនជន្មាយុដ៏ថ្លៃថ្លាដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៦ នេះ ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមប្រសិទ្ធពរជ័យជូនចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឌិត មុន្នី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលបាននូវបញ្ញាញាណក្លឹថ្លាវាងវៃ កម្លាំងពលំមាំមួន ជន្មាយុយឺនយូរ ចាកផុតពីរោគាព្យាធិនានា និងសម្រេចជោគជ័យដ៏ត្រចះត្រចង់ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** ក្នុងការចូលរួមធានាការពារឯករាជ្យជាតិ អធិបតេយ្យភាព បូរណភាពដែនដី ការលើកតម្កើងកិត្យានុភាពរបបរាជានិយមឱ្យទទួលបានការគាំទ្រពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ក្រោមម្លប់ដ៏ត្រជាក់ **ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ ជូនចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឌិត មុន្នី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ចភាពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០២៦

តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

រដ្ឋមន្ត្រី

ហេង សួរ